Khmer

Australian Government
Attorney-General's Department

# រក្សាប្រទេសអូស្ត្រាលីឲ្យមានសុវត្ថិភាព។
# រក្សាការផ្តល់ពត៌មានឲ្យបានជាប់ជាបន្ត

**NATIONAL SECURITY HOTLINE**
**1800 1234 00**

អ្នកឆ្លើយទូរស័ព្ទដែលមានការបណ្តុះបណ្តាលយកចិត្តទុក ដាក់យ៉ាងខ្លាំងចំពោះរឿងរាល់ទូរស័ព្ទទាំងអស់។

លោកអ្នកមិនចាំបាច់ប្រាប់ឈ្មោះរបស់លោកអ្នកឡើយ។

## សន្តិសុខជាតិ - រឿងរាល់ពត៌មានលំអិតសុទ្ធតែមាន ប្រយោជន៍

រឿងរាល់ពត៌មានតិចតួចដែលយើងទទួលពីសាធារណៈជន នៅថ្ងៃនេះ អាចមានប្រយោជន៍ក្រៃលែងក្នុងការធ្វើឲ្យប្រទេសអូស្ត្រាលីមានសុវត្ថិភាព ដើម្បីគេចផុតពីភេរវកម្មនៅថ្ងៃស្អែក។ ជាញឹកញយ ពត៌មានលំអិតតូចតាចជាងគេទាំងនោះហើយដែលធ្វើឲ្យមានការផ្លាស់ប្តូរធំបង្អស់នោះ។ ដូច្នេះ ប្រសិនបើ លោកអ្នកមើលឃើញ ឬស្តាប់ឮអ្វីមួយដែលលោកអ្នកយល់ថាមិនត្រឹមត្រូវនោះ សូមទាក់ទងខ្សែទូរស័ព្ទពិសេសផ្នែក សន្តិសុខជាតិ ហើយរក្សាការផ្តល់ពត៌មានឲ្យបានជាប់ជាបន្ត។

## តើ ខ្សែទូរស័ព្ទពិសេសផ្នែកសន្តិសុខជាតិ ជាអ្វី?

ខ្សែទូរស័ព្ទពិសេសផ្នែកសន្តិសុខជាតិ **(1800 1234 00)** គឺជាលេខទូរស័ព្ទឥតគិតថ្លៃ ដែលតភ្ជាប់លោកអ្នកទៅនឹងអាជ្ញាធរទាំងឡាយ ដើម្បីរាយការណ៍ប្រាប់អំពីសកម្មភាពរបស់ភេរវជនដែលអាចកើតមាននៅក្នុងប្រទេសអូស្ត្រាលី។ លេខទូរស័ព្ទពិសេសនេះធ្វើការ២៤ម៉ោង ក្នុង១ថ្ងៃ ៧ថ្ងៃក្នុង១អាទិត្យ។ នេះគឺជាការសំខាន់ដែលត្រូវរក្សាការផ្តល់ពត៌មានឲ្យបានជាប់ជាបន្ត – រឿងរាល់ពត៌មានតិចតួចដែលយើងទទួលពីសាធារណៈជននៅថ្ងៃនេះ អាចមានប្រយោជន៍ក្រៃលែងក្នុងការធ្វើឲ្យប្រទេសអូស្ត្រាលីមានសុវត្ថិភាព ដើម្បីគេចផុតពីភេរវកម្មនៅថ្ងៃស្អែក។

## តើមានអ្វីខ្លះដែលគួររាយការណ៍ទៅ ខ្សែទូរស័ព្ទពិសេសផ្នែកសន្តិសុខជាតិ?

ពួកភេរវជនពឹងផ្អែកទៅលើការវាយឆ្មក់ ហេតុដូច្នេះហើយ ជាការលំបាកក្នុងការផ្តល់ដល់សាធារណៈនូវបញ្ជីជាក់លាក់នៃសញ្ញាភេរវកម្មដែលអាចកើតមានណាមួយ។ ទោះជា យ៉ាងណាក្តី បទពិសោធន៍តាមតំបន់ និងពីបរទេសបានផ្តល់មកយើងនូវសញ្ញាព្រមានដែលអាចកើតមានខ្លះៗ ដែលយើងត្រូវឃ្លាំមើល។ ក្នុងកាលភ្នាក់ងារសន្តិសុខអូស្ត្រាលីកំពុងធ្វើការយ៉ាងខ្លាំងក្លាដើម្បីការពារប្រទេសអូស្ត្រាលីពីអំពើ ភេរវកម្ម សមាជិកសាធារណៈអាចជួយផ្តល់ព័ត៌មានឲ្យបានពេញលេញផងដែរ។ កូនសៀវភៅនេះផ្តល់នូវឧទាហរណ៍ខ្លះៗ ប៉ុណ្ណោះអំពីអ្វីៗដែលយើងត្រូវឃ្លាំមើល។

### ការថតកាសែតវីឌីអូ ឬការថតរូបខុសប្លែកពីធម្មតានូវអាគារ ផ្លូវការ ឬហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗឯទៀត

ការថតកាសែតវីឌីអូ គឺជាមធ្យោបាយមួយ ក្នុងចំណោម មធ្យោបាយឯទៀតដែលពួកភេរវជនប្រមូលយកព័ត៌មានអំពីគោលដៅដែលគេត្រូវវាយប្រហារ។ ប្រសិនបើលោកអ្នក ឃើញនរណាម្នាក់ប្រើវីឌីអូ ម៉ាស៊ីនថត ឬទូរស័ព្ទមានម៉ាស៊ីនថតក្នុងលំនាំមួយដែលគួរឲ្យសង្ស័យ (ហើយមើលទៅគេមិន មែនដូចជាអ្នកទេសចរណ៍ទាល់តែសោះ) សូមរាយការណ៍អំពីរឿងនេះ។

### រថយន្តគួរឲ្យសង្ស័យនៅក្បែរអាគារសំខាន់ៗ ឬនៅក្បែរទី កន្លែងប្រជុំជន

ពួកភេរវជនប្រើរថយន្តសំរាប់គោលដៅផ្សេងគ្នាជាច្រើន ចាប់ពីការឈ្លបមើល ទៅការដាក់គ្រាប់បែក។ រថយន្តប្រហែលជាចតក្នុងរយៈពេលយ៉ាងយូរខុសផ្លែកពីធម្មតា ជួនកាលនៅតាមកន្លែងហាមឃាត់មិនឲ្យចត។ គ្រឿងផ្ទុះអាចមានទម្ងន់ធ្ងន់ដែលឡាន និងឡានវែងធម្មតាអាចមើល ទៅដូចជាទ្រោបទាបចុះពីលើប្រព័ន្ធទ្រត្រួររបស់វាខុសពីធម្មតា។ ឡានទាំងនេះអាចហួសពេលកំណត់ចុះឈ្មោះ ឬមានលេខ ផ្លាកឡានក្លែងបន្លំ ឬឥតមានលេខផ្លាកឡានទាល់តែសោះ។

### សេចក្តីត្រូវការទីស្នាក់អាស្រ័យដែលគួរឲ្យសង្ស័យ

ជួនកាល មនុស្សប្រើ ជួល ឬទិញទីស្នាក់អាស្រ័យក្នុងវិធី មួយដែលគួរឲ្យសង្ស័យ ដែលគេប្រហែលជាធ្វើការសំរបសំរួលភេរវជនវាយប្រយុទ្ធ។ នៅប្រទេសអង់គ្លេស យានដ្ឋាន ជួលមួយត្រូវបានគេយកប្រើជារោងចក្រផលិតគ្រាប់បែក។ សមាជិកសាធារណៈម្នាក់បានរាយការណ៍ប្រាប់អំពីការចេញ ចូលចុះឡើងដ៏ចម្លែកនៃពួកជនដែលពាក់ស្រោមដៃ ហើយការនេះបាននាំមកនូវការចាប់ខ្លួននៃពួកភេរវជនដែលបានវាយ ប្រហារអាកាសយានដ្ឋាន Heathrow Airport ចំនួនបីលើករួចមកហើយ។

### ការទិញដ៏ចម្លែកខុសពីធម្មតានូវសារធាតុគីមី គ្រឿងផ្ទុះ ហើយនិងគ្រឿងបរិក្ខាការពារ

សារធាតុគីមីត្រូវបានគេយកប្រើនៅក្នុងភេរវជនវាយប្រយុទ្ធ ពេញទូទាំងពិភពលោក។ សារធាតុគីមីទាំងនេះជាផលិតផលទូទៅសំរាប់ប្រើប្រាស់ក្នុងផ្ទះ ផ្នែកកសិកម្ម ការព្យាបាលសត្វ ឧស្សាហកម្ម ហើយនិងការកែសម្ផស្ស។ ប្រសិនបើលោកអ្នកមើលឃើញការទិញដ៏ចម្លែកខុសពីធម្មតា នូវសារធាតុគីមី និងគ្រឿងបរិក្ខាការពារណាមួយ សូមរាយការណ៍ទៅខ្សែទូរស័ព្ទពិសេសផ្នែកសន្តិសុខជាតិ។

## មានអ្វីមួយដែលគួរឲ្យសង្ស័យ

មនុស្សដែលគិតបំរុងនឹងប្រព្រឹត្តអំពើភេរវកម្មអាចប្រព្រឹត្ត អាកប្បកិរិយាក្នុងលំនាំមួយដែលខុសប្លែកពីធម្មតា ឬគួរឲ្យ សង្ស័យ ឬសំណូមពររបស់គេដូចជាគួរឲ្យសង្ស័យផងដែរ។ ឧទាហរណ៍នៃអាកប្បកិរិយាដែល ’គួរឲ្យសង្ស័យ’ បាន បង្ហាញឲ្យឃើញនៅក្នុងពួកភេរវជនដែលជាអ្នកទទួលខុស ត្រូវចំពោះការវាយប្រហារកាលពីថ្ងៃទី១១ ខែកញ្ញា នៅសហរដ្ឋអាមេរិក។ គេបានទទួលការហ្វឹកហ្វឺនបើកបរ យន្តហោះ ក៏ប៉ុន្តែគេមិនចង់រៀនហោះឡើងពីដី ឬចុះដីទេ។ ទោះថា មានអ្វីដែលគួរ ឬមិនគួរឲ្យសង្ស័យនោះ គឺអាចពឹងផ្អែកទៅ លើកាលៈទេសៈទាំងឡាយ។
សូមឃ្លាំមើលស្ថានការណ៍ឲ្យបាន ពេញលេញ។ ប្រសិនបើសកម្មភាពរបស់ជនណាម្នាក់ធ្វើឲ្យ លោកអ្នកកើតមានកង្វល់ ដោយសារអាកប្បកិរិយារបស់គេ ដែលមើលទៅគួរឲ្យសង្ស័យ សូមទូរស័ព្ទខ្សែទូរស័ព្ទពិសេសផ្នែក សន្តិសុខជាតិ ធ្វើការ២៤ម៉ោង លេខ **1800 1234 00**។

## អត្តសញ្ញាណក្លែងបន្លំ ឬមានច្រើនសណ្ឋាន

មនុស្សដែលកំពុងរៀបគ្រោងអំពើភេរវកម្ម ជាញឹកញយប្រើ ឯកសារដែលបានលួច ឬក្លែងបន្លំ មានរួមទាំងប័ណ្ណឥណ ទាន លិខិតឆ្លងដែន ហើយនិងប័ណ្ណបើកបររថយន្ត។ ពួកគេ ក៏ប្រហែលជាមានអត្តសញ្ញាណច្រើនសណ្ឋានផងដែរដែល អាចផ្តល់ពត៏មានប្រទាំងគ្នា ដល់អ្នកដែលគេទាក់ទងជាមួយ។

**សូមចងចាំថាៈ** ជាញឹកញយ ពត៏មានលំអិតតូចតាចជាង គេទាំងនោះហើយ ដែលធ្វើឲ្យមានការផ្លាស់ប្តូរធំបង្អស់នោះ។ ប្រសិនបើលោកអ្នកមើលឃើញ ឬមានការដឹងយល់អំពី អាកប្បកិរិយាណាមួយដែលជាកង្វល់ដល់លោកអ្នក សូម កត់ចំណាំនូវពត៏មានឲ្យបានច្រើន ដែលអាចធ្វើទៅបាន។
ពត៏មានលំអិតទាំងឡាយ ដែលអាចជួយដល់អាជ្ញាធរមាន រួមទាំងៈ អាសយដ្ឋានផ្លូវថ្នល់ ថ្ងៃទី ពេលវេលា លេខទូរស័ព្ទ លេខផ្លាកឡាន ហើយនិងការពិពណ៌នាទាំង ឡាយ។

# ពត៏មានទាក់ទង

ប្រសិនបើលោកអ្នកមើលឃើញ ឬស្តាប់ឮអ្វីមួយដែលលោក អ្នកយល់ថាមិនត្រឹមត្រូវនោះ សូមទាក់ទងខ្សែទូរស័ព្ទពិសេស ផ្នែកសន្តិសុខជាតិ ហើយរក្សាការផ្តល់ពត៏មានឲ្យបានជាប់ ជាបន្ត។ សូមចងចាំថាៈ ជាញឹកញយ ពត៏មានលំអិតតូច តាចជាងគេទាំងនោះហើយ ដែលធ្វើឲ្យមានការផ្លាស់ប្តូរធំ បង្អស់នោះ។

ទូរស័ព្ទៈ **1800 1234 00**

អ៊ីម៉េលៈ hotline@nationalsecurity.gov.au

វ៉ិបសាយៈ australia.gov.au/nationalsecurity